**សេចក្តីប្រកាសព័ត៌មាន**

## ស្ថានទូតអូស្ត្រាលី ភ្នំពេញ

ថ្ងៃទី ០២ ធ្នូ ឆ្នាំ២០១៩

## ប្រទេសអូស្ត្រាលី ទទួលបាន
## ការទទួលស្គាល់សម្រាប់ការគាំទ្រការងារបោសសម្អាតមីន

ស្ថានទូតអូស្ត្រាលី ព្រមទទួលការបំពាក់មេដាយ គ្រឿងឥស្សរិយយស ពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការទទួលស្គាល់ការគាំទ្រដ៏យូរអង្វែងរបស់អូស្ត្រាលី ចំពោះការងារបោសសម្អាតមីននៅកម្ពុជា។

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ *អេនជេលឡា ខកខឺរ៉េន* នឹងទទួលបានគ្រឿងឥស្សរិយយស**សហមេត្រី** ថ្នាក់មហាសិរីវឌ្ឍន៍ ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃចន្ទ ទី០២ ខែធ្នូ។

លោកជំទាវ *អេនជេលឡា ខកខឺរ៉េន* មានប្រសាសន៍ថា៖ «នាងខ្ញុំ មានសេចក្តីសោមនស្សរីករាយ ដែលរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់តួនាទីដ៏សំខាន់របស់ប្រទេសអូស្ត្រាលី ក្នុងការជួយគាំទ្រដល់ការបោសសំអាតមីននៅកម្ពុជា អស់រយៈពេល ២៥ ឆ្នាំកន្លងមក»។

លោកជំទាវ *អេនជេលឡា ខកខឺរ៉េន* បន្ថែមថា៖ «ពេលដែលយើងចាប់ផ្តើមការងារបោសសម្អាតមីននៅកម្ពុជាដំបូង កាលនោះមានអ្នកស្លាប់ដោយសារគ្រាប់មីនជាង៤០០០នាក់ ជារៀងរាល់ឆ្នាំ។ ជំនួយរបស់អូស្ត្រាលី បានជួយកាត់បន្ថយអត្រាអ្នករងគ្រោះដោយសារមីន មកត្រឹម៥៨នាក់ កាលពីឆ្នាំមុន»។

ជំនួយរដ្ឋាភិបាលអូស្ត្រាលីក្នុងវិស័យបោសសម្អាតមីននៅកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ១៩៩៤ ដោយបានផ្តល់ថវិកាសរុបជាង១០០លានដុល្លារអូស្ត្រាលី។

ចាប់តាំងពីឆ្នាំ២០០៦ អូស្ត្រាលីបានចាប់ដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង អាជ្ញាធរមីន (CMAA) ក្នុងការបោសសម្អាតចំការមីន និងផ្សព្វផ្សាយសហគមន៍អំពីហានិភ័យនៃគ្រាប់មីន។ តាមរយៈភាពជាដៃគូនេះ ដីចំការមីនទំហំជាង ២៣៩គីឡូម៉ែត្រការ៉េ ត្រូវបានបោសសម្អាត និងផ្តល់ទៅឲ្យសហគមន៍មូលដ្ឋានសម្រាប់ធ្វើកសិកម្ម។

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au